# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

## កិច្ចខិតខំប្រឹងប្រែងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ឆ្នាំ២០២២ ពង្រឹងភាពជាដៃគូ ក្នុងវិស័យការពារជាតិ របស់អូស្ត្រាលីនិងកម្ពុជា

ក្នុងសប្តាហ៍នេះ សកម្មភាពចូលរួមក្នុងតំបន់ដ៏សំខាន់របស់អូស្ត្រាលី ហៅថា Indo-Pacific Endeavor (IPE) បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ដោយយកមកជាមួយនូវ គ្រូបង្វឹកកងកម្លាំងការពារជាតិអូស្ត្រាលី។ គ្រូបង្វឹកទាំងនេះបានបំពេញការងារនៅ វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាព និងបោសសំអាតមីន (IPMEC) នៅឧដុង្គ ដើម្បីផ្តល់ការបណ្តុះបណ្តាលផ្នែករក្សាសន្តិភាព ដល់កងកម្លាំងរក្សាសន្តិភាពរបស់កងយោធពលខេមរភូមិន្ទ (RCAF) ដែលត្រៀមដាក់ពង្រាយ ក្រោមប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ។ គ្រូបង្វឹកកងកម្លាំងការពារជាតិអូស្ត្រាលីចំនួនប្រាំរូប បានធ្វើការងារជាមួយសហការី មកពីកងយោធពលខេមរភូមិន្ទ ដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលរបស់អង្គការសហប្រជាជាតិ ស្តីពីការការពារកុមារនិង យេនឌ័រ ក្នុងកិច្ចប្រតិបត្តិការយោធាដល់កងកម្លាំងរក្សាសន្តិភាព របស់កងយោធពលខេមរភូមិន្ទ ដែលមានចំនួនប្រហែលជា ៤០រូប។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ យើងក៏មានកម្មវិធីបណ្តាញស្ត្រីផងដែរ។

កម្មវិធី IPE កំពុងធ្វើទស្សនកិច្ច ក្នុងប្រទេសចំនួន១៤ ចាប់ពីចុងខែកញ្ញា ដល់ចុងខែវិច្ឆិកា ដើម្បីគាំទ្រ ដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការពង្រឹងភាពជាដៃគូយោធា នៅទូទាំងអាស៊ីអាគ្នេយ៍ និងមហាសមុទ្រឥណ្ឌាភាគឦសាន។ កម្មវិធី IPE ពង្រឹងការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ចំពោះការជំរុញអោយមានតំបន់ដែលមាន ភាពបើកចំហ បរិយាបន្ន និងភាពធន់។ សកម្មភាពនានា ក្នុងកម្មវិធីនេះរួមមាន សមយុទ្ធយោធា សិក្ខាសាលា ការបណ្តុះបណ្តាល កីឡា និងព្រឹត្តិការណ៍វប្បធម៌។

នៅក្នុងពិធីបិទវគ្គ ក្នុងថ្ងៃនេះ ឧត្តមសេនីយ៍ទោ Kathryn Toohey តំណាងយោធាជាន់ខ្ពស់អូស្ត្រាលី បានមានប្រសាសន៍ថា លោកជំទាវមានសេចក្តីរីករាយ ដែលបានវិលត្រឡប់មកកម្ពុជាជាថ្មីម្តងទៀត ដោយលោកជំទាវធ្លាប់បានបំពេញការងារជាមួយ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ

នៅ កម្ពុជា (UNTAC) ក្នុងអំឡុងឆ្នាំ ១៩៩២-១៩៩៣ ហើយបានមានប្រសាសន៍បន្ថែមថា "អូស្ត្រាលីមានមោទនភាពចំពោះសមិទ្ធិផលដ៏អស្ចារ្យរបស់ខ្លួន ក្នុងផ្នែករក្សាសន្តិភាពរួមទាំងនៅប្រទេសកម្ពុជាផងដែរ ហើយយើងក៏ប្រារព្ធខួបទី៣០ឆ្នាំនៃអ៊ុនតាក់ នៅក្នុងឆ្នាំនេះផងដែរ។ យើងបន្តនូវឆន្ទៈ ក្នុងការអភិវឌ្ឍកិច្ចសហប្រតិបត្តិការការពារជាតិរបស់យើងរួមទាំងការងារនានាតាមរយៈការរក្សាសន្តិភាព»។

ឯកអគ្គរាជទូត Pablo Kang បានថ្លែងអំណរគុណដល់កម្ពុជា ដែលបានរៀបចំវគ្គបណ្តុះបណ្តាលនេះ និងធ្វើឱ្យ IPE22 ទទួលបានជោគជ័យ។ ឯកឧត្តមបានសង្កត់ធ្ងន់ អំពីការរីកចម្រើនរបស់កម្ពុជា ដែលបានក្លាយខ្លួនពីប្រទេសទទួលការរក្សាសន្តិភាព ទៅជាប្រទេសរួមចំណែករក្សាសន្តិភាពដ៏សំខាន់ នាពេលបច្ចុប្បន្ននេះ ហើយបានមានប្រសាសន៍ថា "អូស្ត្រាលីប្តេជ្ញាធ្វើការងាររួមគ្នាជាមួយកម្ពុជា ដើម្បី បង្កើតតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ដែលមានការចូលរួម កិច្ចសហប្រតិបត្តិការ និងលំនឹងយុទ្ធសាស្ត្រ"។

ឯកឧត្តមបានបន្ថែមថា "ដំណើរទស្សនកិច្ចនេះ កើតឡើង ក្រោយពីខួបទី៣១ឆ្នាំនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបានត្រួសត្រាយផ្លូវសម្រាប់ការបញ្ចប់ជម្លោះជាច្រើនទសវត្សរ៍នៅកម្ពុជា។ កិច្ចព្រមព្រៀងនេះ បាននាំមកនូវបេសកកម្មអ៊ុនតាក់ ដែលមានកងកម្លាំងការពារអូស្ត្រាលី ជាស្ត្រី និងបុរស ជាច្រើនរូបរួមទាំងឧត្តមសេនីយ៍ទោ Toohey ផងដែរ ដែលបានចូលរួមបម្រើការងារប្រកបដោយឧត្តមភាព។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au